ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

139

<u>តុលាការកំពូល</u>

សំណុំរឿង ព្រហ្មទណ្ឌ

លេខ : ១៤

ចុះថ្ងៃទី១១ខែកុម្ភៈឆ្នាំ២០០៣

<u>សាលដីកា</u>

លេខ : ០៨

ចុះថ្ងៃទី១០ខែមិនាឆ្នាំ២០០៤

តាងនាមប្រជារាស្ត្រខ្មែរ

តុ លា ការ កំ ពូ ល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន
២ - លោក ណឹម ស៊ីផល ចៅក្រម
៣ - លោក ជីវ កេង ចៅក្រម
៤ - លោក ព្រាក់ គឹមសាន ចៅក្រម
៥ - លោក សោម សិរីវឌ្ឍ ចៅក្រមរបាយការណ៍
អ្នកស្រី សុខុន សុមាលីកា ក្រឡាបញ្ជី
តំណាងមហាអយ្យការ
លោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកា ព្រហ្មទណ្ឌលេខ ៦២ "ង" ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ១៤ ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៣ របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះ សូ រិទ្ធី "ដុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៣៨ឆ្នាំ មុខរបរ បុគ្គលិកទីប្រៃសណីយ៍ កើតនៅភូមិកំពង់សំណាញ់ ឃុំ-ស្រុកតាខ្មៅ ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃនៅផ្ទះលេខ ៧៨ស៊ី , ផ្លូវលេខ១៣៤ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ សូ ប៊ុច "រ" ម្តាយឈ្មោះ ទឹម សឿន "រ" ប្រពន្ធឈ្មោះ លឹម ចាន់ភាព មានកូន ០២ នាក់ ។
ចាប់ខ្លួនថ្ងៃទី ១២ - ៣ - ២០០២ ឃុំខ្លួនថ្ងៃទី ១៤ - ៣ - ២០០២ ។

- មេធាវី : គ្មាន

- ត្រូវចោទពីបទ : ចោរកម្ម "លួចបើកច្រកប្រពន្ធ័ទូរសព្ទ៍អន្តរជាតិ" ប្រព្រឹត្ត នៅក្រុងភ្នំពេញ កាលពីថ្ងៃទី ២៨ - ០២ - ២០០២ ។

- ដើមបណ្តឹងរដ្ឋប្បវេណី មន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានលោក ថែម សង្វារ និងលោក កិត ស្រៀង "ម្ចាស់បណ្តឹងសាទុក្ខ" ។

- តាមពាក្យបណ្តឹងរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចុះថ្ងៃទី ២៧ ខែ១ - កុម្ភៈ ឆ្នាំ ២០០២ បញ្ជាក់ថា មានក្រុមស្រាវជ្រាវបទល្មើសបានរកឃើញជនល្មើសឈ្មោះ យឹម វណ្ណះ បានដាវបណ្តាញទូរស័ព្ទក្រុមហ៊ុនម៉ូប៊ីថែលច្រើនគ្រឿង យកទៅបំពាក់ឧបករណ៍ទំនើប បើកច្រកអន្តរជាតិខុសច្បាប់ ដែលធ្វើឲ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បាត់បង់ចំណូល ៧៣ ម៉ឺនដុល្លា ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់អយ្យការអមតុលាការក្រុងភ្នំពេញថា ៖ សុំចោទប្រកាន់ឈ្មោះ លូ រិទ្ធី ភេទប្រុស អាយុ៣៦ឆ្នាំ និងគូកន ឈ្មោះ ល្វី សងីហ្វូ ភេទប្រុស អាយុ ៤០ឆ្នាំ ឈ្មោះ ប៉ុន សុភាព ភេទស្រី អាយុ ២១ឆ្នាំ ឈ្មោះ យឹម វណ្ណះ ភេទប្រុស អាយុ ៣០ឆ្នាំ ពីបទចោរកម្ម "លួចបើកច្រកប្រព័ន្ធទូរស័ព្ទអន្តរជាតិ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៨ ខែ១ កុម្ភៈ ឆ្នាំ ២០០២ ។

- បានឃើញដីកាឃុំខ្លួនលេខ ៣៨៤ ចុះថ្ងៃទី ១៤ - ៣ - ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើឈ្មោះ លូ រិទ្ធី ពីបទ ចោរកម្ម .

- បានឃើញដីកាសំរេចលេខ ៣៦២២ត្រ ចុះថ្ងៃទី ១៨ - ៦ - ២០០២ របស់ចៅក្រមស៊ើបអង្កេត ដែលមានខ្លឹមសារសំរេច ៖

១ - ឲ្យឈ្មោះ លូ រិទ្ធី ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ របរកសុី បុគ្គលិកប្រៃសណីយ៍ ទីលំនៅផ្ទះលេខ ៧៨អុី ផ្លូវលេខ១៣៤ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ដែលជាប់ចោទពីបទ ចោរកម្ម "លួចបើកច្រកប្រព័ន្ធទូរស័ព្ទអន្តរជាតិ" ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៨ ០២ ២០០២ ហើយត្រូវបានឃុំខ្លួននៅពន្ធនាគារនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ "ទេបញ្ញី" លេខឃុំខ្លួន ៣៨៤ ចុះថ្ងៃទី ១៤ - ៣ - ២០០២ ឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ។

២ - បង្គាប់មកលោកប្រធានមន្ទីរពន្ធនាគារស្នងការនគរបាលរាជធានីភ្នំពេញ "ទេបញ្ញី" ឲ្យដោះលែងជាបន្ទាន់ឈ្មោះ លូ រិទ្ធី ប្រសិនបើឈ្មោះនេះមិនត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀតទេ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៥៦ ចុះថ្ងៃទី០៤ - ៧ - ២០០២ របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តវ៉ាពីដីកាសំរេចលេខ ៣៦២២ត្រ ចុះថ្ងៃទី ១៨ - ៦ - ២០០២ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា ៖

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៤ - ៧ - ២០០២ របស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - សាលាឧទ្ធរណ៍សំរេចតាមការយល់ឃើញ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៦២ "ង" ចុះថ្ងៃទី ៣១ - ៧ - ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសេចក្តីសំរេច ៖

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៤ - ៧ - ២០០២ របស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយផ្ទុយនិងគតិច្បាប់ ។

២ - តំកល់ដីកាសំរេចឱ្យជនជាប់ចោទឈ្មោះសូ រិទ្ធី នៅក្រៅឃុំបណ្តោះអាសន្នលេខ ៣៦២២តព្រ ចុះថ្ងៃទី ១៨ - ៦ - ២០០២ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ទុកជាបានការ

៣ - សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ អ្នកធានា ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី ។

-បានឃើញបណ្តឹងសាទុក្ខលេខ ៣១ ចុះថ្ងៃទី ០៦ - ៨ - ២០០២ របស់លោក ថែម សង្ការ កិត ស្រៀង "តំណាងឱ្យក្រសួងទំប្រឈើជី តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៦២ "ង" ចុះថ្ងៃទី៣១ - ៧ - ២០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី ០១ - ៩ - ២០០៣ របស់លោក ថែម សង្ការ មាន លក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី ០៥ - ១១ - ២០០៣ របស់លោក សូ រិទ្ធី មាន លក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា :

. បទល្មើសនេះជាបទល្មើសមជ្ឈឹម ជនជាប់ចោទមានអ្នកធានាត្រឹមត្រូវ មានទីលំនៅច្បាស់លាស់ ។

. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦២ "ង" ចុះថ្ងៃទី ៣១ - ៧ - ២០០២ របស់សាលាឧទ្ធរណ៍

-បានស្តាប់សាវតាជាតិ និងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី សារណាតបរបស់ជនជាប់ចោទ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា : សូមតម្កល់សេចក្តីសន្និដ្ឋាន ទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សារណា របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុ លា កា រ កំ ពូ ល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣១ ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០០២ របស់ឈ្មោះ ថែម សង្ការ និងកិត ស្រៀង ធ្វើទៅក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលដើមបណ្តឹងរដ្ឋប្បវេណី លើកទៅក្នុងសារណាការពារ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ២០០៣ថា តុលាការក្រុងភ្នំពេញ និងសាលាឧទ្ធរណ៍ឱ្យជនជាប់ចោទនៅក្រៅឃុំ ដោយពុំមានដាក់ប្រាក់ធានាសំរាប់ទូទាត់សំណងអន្តរាយទេ ហើយថាតុលាការពុំបានចាត់វិធានការ ការពារផលប្រយោជន៍ដើមបណ្តឹងនោះ គឺថាការភ័ន្តច្រឡំ ដោយហេតុថា : ការលួចធ្វើអាជីវកម្មរបីករេល

 142

ទូរស័ព្ទទៅក្រៅប្រទេសតាមប្រព័ន្ធ អ៊ីនធឺណែត ពុំមែនជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសពីបទចោរកម្ម តាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- យល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទ បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦២ "ង" ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទ
ប៉ុន្តែចាត់ទុកជាចំពោះមុខ .

១ - ទទួលបណ្ដឹងសាទុក្ខលេខ ៣១ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០០២ របស់ឈ្មោះថែម សង្ហារ និងកិត ស្រ៊ាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តំកល់សាលដីកាព្រហ្មទណ្ឌលេខ ៦២ "ង" ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ១៤ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការកំពូលទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្ដី ។

៤ - សាលដីកានេះជំនុំជំរះនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០០៤ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៤ ។